# ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា
CAMBODIA WATCHDOG COUNCIL INTERNATIONAL

ក្រុងគ្រីស្ទានសាន់ (ប្រទេសន័រវែស) ថ្ងៃទី២១ ខែមករា ឆ្នាំ២០២២

## សេចក្តីថ្លែងការណ៍
## តើពន្លឺយុត្តិធម៌នៅឯណា សម្រាប់លោក ជា វិជ្ជា រយៈពេល ១៨ ឆ្នាំមកនេះ?

ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា សូមរំលឹកថាកាលពី ១៨ឆ្នាំមុន លោក **ជា វិជ្ជា** ជាមេដឹកនាំសហជីពសេរីកម្មករ និងជាសមាជិកស្ថាបនិកនៃក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា ត្រូវបានឃាតក បាញ់សម្លាប់នៅថ្ងៃទី ២២ ខែមករា ឆ្នាំ២០០៤ ជាឃាតកម្ម មានជាប់ពាក់ព័ន្ធនឹងលោក **ហុក ឡុងឌី** អតីតមេប៉ូលីសជាតិនៃក្រសួងមហាផ្ទៃ និងជាជន្លងរបស់លោក នាយករដ្ឋមន្ត្រី **ហ៊ុន សែន**។

គួរកត់សម្គាល់ថា លោក **ហេង ពៅ** អតីតស្នងការនគរបាលរាជធានីភ្នំពេញ ដែលបច្ចុប្បន្នកំពុងជាប់ពន្ធនាគារ គឺជាសាក្សីយ៉ាងសំខាន់បំផុតក្នុងសំណុំរឿងឃាតកម្មលោក **ជា វិជ្ជា** ។ ក្រៅពីនេះ នៅមានមន្ត្រីប៉ូលីសមួយចំនួនទៀត ក៏ពាក់ព័ន្ធក្នុងសំណុំរឿងលោក ជា វិជ្ជា ដែរ នៅក្រោមអំណាចបញ្ជារបស់លោក **ហុក ឡុងឌី** កាលនោះ។

កាលនៅរស់ លោក **ជា វិជ្ជា** ត្រូវបានគេគំរាមសម្លាប់នៅខែកក្កដា ឆ្នាំ២០០៣ តាមសារជាអក្សរផ្ញើចូលទូរស័ព្ទរបស់ លោក ដែលជាលេខទូរស័ព្ទរបស់មន្ត្រីប៉ូលីសជាន់ខ្ពស់នៃ ក្រសួងមហាផ្ទៃ។ ពេលនោះលោក **ជា វិជ្ជា** ក៏ធ្លាប់និយាយប្រាប់ពួក យើងខ្ញុំជាមិត្តជិតស្និទ្ធផង និងជាក្រុមការងារនៃក្រុមប្រឹក្សាឃ្លាំមើលកម្ពុជាផង ដោយបញ្ជាក់ទាំងទឹកមុខស្លូតថា **«មន្ត្រីជាន់ខ្ពស់ពីក្រសួងមហាផ្ទៃ នៅក្រោមបញ្ជាមេប៉ូលីសកំពូល គំរាមសម្លាប់ខ្ញុំ»**។

សំណុំរឿងនេះ នៅតែមិនទាន់អាចរកពន្លឺយុត្តិធម៌បាននៅឡើយមកទល់សព្វថ្ងៃ។ ដោយឡែក ការធ្វើមិនដឹងមិនឮរបស់លោក នាយករដ្ឋមន្ត្រី **ហ៊ុន សែន** ក្នុងសំណុំរឿងឃាតកម្មលោក **ជា វិជ្ជា** នេះ បានធ្វើឲ្យពលរដ្ឋខ្មែរ មានមន្ទិលសង្ស័យពីការរួមគំនិត ឬការគប់គិតណាមួយ ក្នុងផែនការសម្លាប់លោក **ជា វិជ្ជា** ដើម្បីជាការព្រមានដោយប្រយោលដល់ គណបក្សសម្ព័ន្ធភាពប្រជាធិបតេយ្យ ជាប់ឆ្នោត ២ ទៀត គឺបក្សហ្វ៊ុនស៊ិនប៉ិចរបស់សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** និងបក្សសមរង្ស៊ីរបស់លោក **សម រង្ស៊ី** ដែលធ្វើឲ្យជាប់គាំងនយោបាយ ជិត ១ឆ្នាំ តាំងពីក្រោយការបោះឆ្នោតជាតិ នៅខែកក្កដា ឆ្នាំ២០០៣ រហូតដល់ខែឧសភា ឆ្នាំ២០០៤ ទើបមានដំណោះស្រាយនយោបាយបាន ស្របតាមរដ្ឋធម្មនុញ្ញ រូបមន្ត ២ ភាគ ៣ ក្នុងការបង្កើតរដ្ឋាភិបាលថ្មី។

យើងខ្ញុំសូមរំលឹកដែរថា ក្នុងចំណោមអង្គការជាសមាជិកនៃ ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា (មាន ៦ អង្គការ សមាគម និង សហជីពជាសមាជិក) ដែលមានតែសហជីពរបស់លោក **ជា វិជ្ជា** ដែលមានកម្លាំងកម្មកររច្រើនជាងគេបំផុត គាំទ្រវាល់ការព្រមានរបស់ ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា និងគណបក្សសម្ព័ន្ធភាពប្រជាធិបតេយ្យ នាំមុខដឹកនាំមហាបាតុកម្មប្រឆាំងលទ្ធផលនៃការបោះឆ្នោត ជាតិ ខែកក្កដា ឆ្នាំ២០០៣ និង មិនទទួលស្គាល់បេក្ខភាពលោក **ហ៊ុន សែន** ជានាយករដ្ឋមន្ត្រី បន្តនៅអាណត្តិថ្មីទៀត។

ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា សូមអំពាវនាវយ៉ាងទទូចថា ដើម្បីជម្រះមន្ទិលសង្ស័យនានា និងបំបាត់អំពើនីទណ្ឌភាព រដ្ឋាភិបាលលោក **ហ៊ុន សែន** និងតុលាការកម្ពុជា ត្រូវជំរុញការស៊ើបអង្កេតឲ្យសកម្ម រួចផ្តល់យុត្តិធម៌ជូនសាច់ញាតិ ក្រុមគ្រួសារ និងអ្នកគាំទ្រលោក **ជា វិជ្ជា** ជានិមិត្តរូបនៃការពង្រឹងនូវប្រព័ន្ធយុត្តិធម៌ថ្លៃថ្នូរ ការអនុវត្តច្បាប់ជាក់លាក់ និងនីតិរដ្ឋ ស្អាតស្អំ។

**ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា**
**ប្រធាន**

**ម៉ែន ណាត**

CWCI Cambodia, address: Senterveien 54, Apartment 112, 4790 Lillesand (town), NORWAY